# ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-១២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៩ បន្ថយរយៈពេលរងទោស អោយជល់ទណ្ឌិត ១៩៤៣

១៧-១២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១២០០/២២១ តម្លើងឋានន្តរសក្តិ ជូនវរសេនីយ៍ឯក គឹម ម៉ិនថាន នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ជាឧត្តមសេនីយ៍ត្រីនគរបាលជាតិនៃក្រសួងមហាផ្ទៃ ១៩៤៧

២២-១២-២០០០ ព្រះរាជក្រឹត្យ នស/រកត/១២០០/២២២ ស្តីពីការតែងតាំងឯកឧត្តម ឡុង សេរីរ័ត្ន ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ១៩៤៨

២២-១២-២០០០ ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៣ ស្តីពីការតែងតាំងឯកឧត្តម តក់ ថាវ ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ១៩៤៩

២២-១២-២០០០ -ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៤ ស្តីពីការតែងតាំងឯកឧត្តម អ៊ុំ ពិសិដ្ឋ ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ១៩៥០

២២-១២-២០០០ -ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៥ ស្តីពីការតែងតាំងឯកឧត្តម ស្នួរ ទេរ៉ា ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ១៩៥១

២២-១២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៦ តែងតាំងលោកតា ម៉ឹង ហ៊ន ជាឧកញ៉ា ១៩៥២

២២-១២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៧ តម្លើងឋានៈស្មើអគ្គនាយក ជូនឯកឧត្តម ខ៊ែត ម៉ូរី នាយករងខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ១៩៥២


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៨-១២-២០០០ - អនុក្រឹត្យ លេខ ៩៩ អនក្រ.បក ស្តីពីការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការ ស៊ីវិល យោធា នគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ ១៩៥៣

២០-១២-២០០០ - អនុក្រឹត្យ លេខ ១០០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៩៥៥
២១-១២-២០០០ - អនុក្រឹត្យ លេខ ១០១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៩៥៦
២០-១២-២០០០ - អនុក្រឹត្យ លេខ ៤១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៥៧
២០-១២-២០០០ - អនុក្រឹត្យ លេខ ៤១៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៥៨
២១-១២-២០០០ - អនុក្រឹត្យ លេខ ៤១៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ នាយនគរបាលជាតិ ១៩៥៩
២២-១២-២០០០ - អនុក្រឹត្យ លេខ ៤២០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៥៩

## ២- សេចក្តីសំរេច

១៩-១២-២០០០ - សេចក្តីសំរេច លេខ ៦៦ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះ អន្តរក្រសួង ដើម្បីស្រាវជ្រាវនិងទប់ស្កាត់បទល្មើសព្រៃឈើ និងបទល្មើសនៃការបរបាញ់សំលាប់សត្វព្រៃ នៅភូមិភាគខាងលិច នៃខេត្តកោះកុង ខេត្តពោធិសាត់ និងខេត្តបាត់ដំបង ១៩៦០

# III- ការិយាល័យក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២១-១២-២០០០ -ប្រកាសលេខ ១០៣៧ ឧរថត.ប្រក. អនុញ្ញាតឱ្យក្រុមហ៊ុន ស្សិតវ៉េ & ឡាវីសាណា ហ្វេសិន ហ្វេតធើរី លីមីធិត (Auit WAY & LASISSACA-FASHION Factory LIMITED) តំណាងដោយ លោក CHUEN HAY សញ្ជាតិ កាណាដា បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ-១៩៦៣. ១៩៦៣

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ១៩៩៨

ត្រាស់បង្គាប់

មាត្រា ១ .-ត្រូវបន្ថយរយៈពេលទទួលរងទោសមកត្រឹម ២០ឆ្នាំ អោយទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ ខាន់ ឈួ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់អស់មួយជីវិត តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី២៨-៥-៩២ របស់តុលាការក្រុងភ្នំពេញ ។

មាត្រា ២ .-ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ឆ្នាំ អោយទណ្ឌិតចំនួន០៤នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ ហ៊ីន ខុច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ "ខ" ចុះថ្ងៃទី០៧-៦-៩៥ របស់តុលាការខេត្តកំពង់ចាម ។

២-ទណ្ឌិតឈ្មោះ មាស សុខហេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី៣០-៥-៩៥ របស់តុលាការក្រុងភ្នំពេញ ។

៣-ទណ្ឌិតឈ្មោះ ម៉ែន គី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី០៩-០១-៩២ របស់តុលាការក្រុងភ្នំពេញ ។

៤-ទណ្ឌិតឈ្មោះ ឌុច ផាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី២៥-៥-៩៥ របស់តុលាការខេត្តព្រៃវែង ។

មាត្រា ៣ .-ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ០៩ខែ អោយទណ្ឌិតចំនួន១៥នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ ខន ខុម ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី១៧-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ ឯក វណ្ណា ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី១៨-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ ឡៀង ឡេង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី២៩-៥-៩៣ របស់តុលាការខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ ស៊ុន រ៉ា ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី១៤-០១-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៥-ទណ្ឌិតឈ្មោះ ទៀ ឧុន្នី ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ២០២ ចុះថ្ងៃទី០៣-១១-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៦-ទណ្ឌិតឈ្មោះលី ហួច ហៅ ម៉ៅ ខុម ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី១៧-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៧-ទណ្ឌិតឈ្មោះ គីម សារិន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី០២-១១-៩២ របស់តុលាការខេត្តបាត់ដំបង ។

៨-ទណ្ឌិតឈ្មោះ ឆោម ឆុន ហៅ ជា គាច ហៅ ឈួន ម៉ិនឈឿន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០១ ចុះថ្ងៃទី២៧-៤-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៩-ទណ្ឌិតឈ្មោះ ពៅ ទីរៈ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៩ ចុះថ្ងៃទី១១-៤-៩៥ របស់ តុលាការខេត្តបាត់ដំបង ។

១០-ទណ្ឌិតឈ្មោះ ខៀន ភឿន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី១៣-២-៩៥ របស់ តុលាការខេត្តបាត់ដំបង ។

១១-ទណ្ឌិតឈ្មោះ ខន់ សាវឿន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ ចុះថ្ងៃទី១៦-៨-៩៤ របស់ តុលាការខេត្តព្រៃវែង ។

១២-ទណ្ឌិតឈ្មោះ ឡេង ឈុនមេង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី០៣-៦-៩៥ របស់ តុលាការខេត្តព្រៃវែង ។

១៣-ទណ្ឌិតឈ្មោះ ឡៅ សុខ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី៣១-០១-៩១ របស់ តុលាការខេត្តកំពង់ស្ពឺ ។

១៤-ទណ្ឌិតឈ្មោះ ហ៊ុន ពៅ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី២៨-១២-៩៥ របស់ តុលាការខេត្តកំពង់ស្ពឺ ។

១៥-ទណ្ឌិតឈ្មោះ ឌូច ហ៊ីម ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី១៦-៦-៩៥ របស់ តុលាការខេត្តកំពង់ស្ពឺ ។

មាត្រា ៤ .-ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ខែ អោយទណ្ឌិតចំនួន៣១នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ មីន ធឿន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ "ត" ចុះថ្ងៃទី២៥-២-៩៨ របស់តុលាការខេត្តកំពង់ចាម ។

២-ទណ្ឌិតឈ្មោះ ជួន ធឿន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី១៨-៥-៩៨ របស់តុលាការខេត្តកំពង់ធំ ។

៣-ទណ្ឌិតឈ្មោះ អ៊ុន សារឹម ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី២២-០១-២០០០ របស់តុលាការខេត្តកំពង់ធំ ។

៤-ទណ្ឌិតឈ្មោះ កែម យិន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី១៩-៣-៩៦ របស់តុលាការខេត្តកំពង់ធំ ។

៥-ទណ្ឌិតឈ្មោះ ហ៊ាន គ្រិល ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៩២ ចុះថ្ងៃទី២២-១០-៩៨ របស់តុលាការខេត្តកំពង់ធំ ។

៦-ទណ្ឌិតឈ្មោះ ផ្លេក តិរម្យ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី១១-៣-៩៨ របស់តុលាការក្រុងព្រះសីហនុ ។

៧-ទណ្ឌិតឈ្មោះ សយ ញ៉ាញ់ ហៅ ល្អិត ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី០៥-២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៨-ទណ្ឌិតឈ្មោះ ម៉ៅ ឌុយ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣៨ ចុះថ្ងៃទី២៩-១១-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៩-ទណ្ឌិតឈ្មោះ គិត សុខា ហៅ ហ៊ឹង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥៨ ចុះថ្ងៃទី១២-១២-៩៥ របស់តុលាការខេត្តបាត់ដំបង ។

១០-ទណ្ឌិតឈ្មោះ យ៉ុត ថូត ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩៧ ចុះថ្ងៃទី២៥-១០-៩៥ របស់តុលាការខេត្ត បាត់ដំបង ។

១១-ទណ្ឌិតឈ្មោះ សួន សារ៉ាត់ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី០៥-៣-៩៨ របស់តុលាការខេត្ត បាត់ដំបង ។

១២-ទណ្ឌិតឈ្មោះ យ៉េម ណារ៉ុង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ១១៧ ចុះថ្ងៃទី២៩-៩-៩៧ របស់តុលាការ ខេត្តបាត់ដំបង ។

១៣-ទណ្ឌិតឈ្មោះ ស្វូ វិមុល ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨៣ ចុះថ្ងៃទី០២-៩-៩៨ របស់តុលាការ ខេត្តបាត់ដំបង ។

១៤-ទណ្ឌិតឈ្មោះ ហម វិរទុធ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២១១ ចុះថ្ងៃទី០៦-១០-៩៨ របស់តុលាការ ខេត្តបាត់ដំបង ។

១៥-ទណ្ឌិតឈ្មោះ ជីវ ជុន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣០ខែ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី០៥-០២-៩៨ របស់តុលាការ ខេត្តបាត់ដំបង ។

១៦-ទណ្ឌិតឈ្មោះ សាក់ គង់ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ ចុះថ្ងៃទី២២-៦-៩៥ របស់តុលាការ ខេត្តព្រៃវែង ។

១៧-ទណ្ឌិតឈ្មោះ គី វណ្ណា ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី២២-០១-៩៩ របស់តុលាការ ខេត្តព្រៃវែង ។

១៨-ទណ្ឌិតឈ្មោះ ប៉ាន់ ពន្សា ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី១៤-០១-៩៨ របស់តុលាការ ខេត្តព្រៃវែង ។

១៩-ទណ្ឌិតឈ្មោះ ញឹម ព្រលឹង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៩ ចុះថ្ងៃទី០៣-១២-៩៨ របស់តុលាការ ខេត្តព្រៃវែង ។

២០-ទណ្ឌិតឈ្មោះ ស៊ឿន ស៊្មោក ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៧ ចុះថ្ងៃទី០១-១២-៩៨ របស់តុលាការ ខេត្តព្រៃវែង ។

២១-ទណ្ឌិតឈ្មោះ សុខ អេង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ៥០ ចុះថ្ងៃទី០១-៧-៩៨ របស់តុលាការ ខេត្តព្រៃវែង ។

២២-ទណ្ឌិតឈ្មោះ គឹម សារ៉ាវុធ ហៅ សីហា ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ០៧ "ជ" ចុះថ្ងៃទី២៥-២-២០០០ របស់តុលាការក្រុងភ្នំពេញ ។

២៣-ទណ្ឌិតឈ្មោះ លាង វណ្ណថា ហៅ ក្រូឡា ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ឆ្នាំ តាមអំណាចសាលដីកាលេខ១៦ ចុះថ្ងៃទី០៣-៥-២០០០ របស់តុលាការកំពូល ។

២៤-ទណ្ឌិតឈ្មោះ នូច ចាន់ ហៅ ធូ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៦ខែ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី១៨-៨-៩៥ របស់តុលាការខេត្តកំពង់ស្ពឺ ។

២៥-ទណ្ឌិតឈ្មោះ ត្រឹម អ៊ុយ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ ចុះថ្ងៃទី២២-១១-៩៤ របស់តុលាការខេត្តកំពង់ស្ពឺ ។

២៦-ទណ្ឌិតឈ្មោះ គិត ម៉េងហុង ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩"ច" ចុះថ្ងៃទី១៦-៨-២០០០ របស់តុលាការក្រុងភ្នំពេញ ។

២៧-ទណ្ឌិតឈ្មោះ សោម រី ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី០៧-៣-៩៥ របស់តុលាការខេត្តកំពង់ស្ពឺ ។

២៨-ទណ្ឌិតឈ្មោះ អ៊ឹម និល ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី០២-១២-៩៣ របស់តុលាការខេត្តកំពង់ស្ពឺ ។

២៩-ទណ្ឌិតឈ្មោះ គង់ ខេម ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី១៦-៦-៩៥ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣០-ទណ្ឌិតឈ្មោះ នុន អាន ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី០២-៦-៩៥ របស់តុលាការខេត្តកំពង់ស្ពឺ ។

៣១-ទណ្ឌិតឈ្មោះ ឃឿន ជាតិ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី២៧-៤-៩៦ របស់តុលាការខេត្តកំពង់ស្ពឺ ។

មាត្រា ៥ .-ត្រូវបានលើកលែងទោសអោយទណ្ឌិតចំនួន ៥នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ ប្រាក់ សំអាត ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣០ ចុះថ្ងៃទី៥-១០-៩៩ របស់តុលាការខេត្តកំពង់ធំ ។

២-ទណ្ឌិតឈ្មោះ ចាន់ ទ្រី ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣"ក" ចុះថ្ងៃទី១២-៨-៩៩ របស់តុលាការក្រុងភ្នំពេញ ។

៣-ទណ្ឌិតឈ្មោះ សុខ សាន្ត ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨"ខ" ចុះថ្ងៃទី៩-៧-៩៦ របស់តុលាការក្រុងភ្នំពេញ ។

៤-ទណ្ឌិតឈ្មោះ អ៊ុច ចាន់ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី២១-០១-៩៥ របស់តុលាការក្រុងព្រះសីហនុ ។

៥-ទណ្ឌិតឈ្មោះ ខេង គំសាន្ត ហៅ សែម ណាំ ដែលត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ខែ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី៥-៨-៩៩ របស់តុលាការក្រុងព្រះសីហនុ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៧ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេចជាស្ថាពរ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/១២០០/២២១

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០០

## ត្រាស់បង្គាប់

**មាត្រា ១** .-ត្រូវបានតម្លើងឋានន្តរស័ក្តិជូនលោកវរសេនីយ៍ឯក គឹម ម៉ុនថាន នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ជាឧត្តមសេនីយ៍ត្រី នគរបាលជាតិនៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/១២០០/២២២

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១០៨២ រស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០០

-យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម ឡុង សេរីរ័ត្ន ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៣

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១០៨៣ រស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០០

-យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម តត់ ថាច ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៤

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១០៨៩ រស ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០

-យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

មាត្រា ១.- តែងតាំងឯកឧត្តម អ៊ី ពិសិទ្ធិ ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

# ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៥

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១០៩៥ រស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០០

-យោងតាមសំណូមពរការងារចាំបាច់

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម សួរ សឿ ជាឧបការីសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៦

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោកតា ម៉ឹង ហ៊ីន

ជា

ឧកញ៉ា

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/១២០០/២២៧

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទទួលយល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-តាមសេចក្តីក្រាបបង្គំទូលថ្វាយ ស្នើសុំអំពីនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០០

**ត្រាស់បង្គាប់**

មាត្រា ១ .- ត្រូវបានតម្លើងឋានៈស្មើ អគ្គនាយក ជូនឯកឧត្តម ខ៊ែត ម៉ូរី នាយករងខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២.- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៩៩ អនក្រ.បក

**ស្តីពី**

**ការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និង យុទ្ធជនពិការ**

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

មាត្រា ១ .- ត្រូវបានអនុញ្ញាតអោយបន្ថែមប្រាក់បៀវត្សចំនួន ១០ភាគរយ លើបៀវត្សសុទ្ធសាធ ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាព ពលកម្ម និងយុទ្ធជនពិការ ។

មាត្រា ២ .- ប្រាក់បៀវត្សដែលបន្ថែម ១០ភាគរយនេះ ត្រូវចាប់អនុវត្ត ពីខែមករា ឆ្នាំ ២០០១តទៅ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ហត្ថលេខា
គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យ លេខ ១០០ អនក្រ.បក

**ស្តីពី**

**ការផ្ទេរតំណែងធានាឧបនិកា**

* * *

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** .- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១២៧.៥០០.០០០រៀល (មួយរយម្ភៃប្រាំពីរលានប្រាំរយពាន់រៀលគត់) ពីជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច) មកជំពូក ៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានអោយអង្គការអន្តរជាតិនានា ) របស់ក្រសួង ពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ។

**មាត្រា ២**.- ឥណទានថវិកា ក្នុងមាត្រា១ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បង់វិភាគទានជូនអង្គការអន្តរជាតិផ្សេងៗ ។

**មាត្រា ៣**.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ហត្ថលេខា
**គាត ឈន់**
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# អនុក្រឹត្យ លេខ ១០១ អនក្រ.បក

## ស្តីពី

## ការផ្ទេរឥណទានថវិកា

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា សរុបចំនួន ២៥ លានរៀលគត់ (ម្ភៃប្រាំលានរៀលគត់) ពីជំពូក៣១ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌) ចំនួន១០ លានរៀល និងពីជំពូក៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា ) ចំនួន១៥លានរៀល មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួង បរិស្ថាន សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ចំណាយសោហ៊ុយទទួលភ្ញៀវបរទេស ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៩១៧ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-តាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំងលោក ម៉ុន្ស សាម៉ឿន ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើនឹង អគ្គនាយករង ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

# អនុក្រឹត្យ លេខ ៩១៨ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ .-** តែងតាំងលោក ខ៊ែន ម៉ុី ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែល មានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៤១៩ អនក្រ.តត
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយឧត្តមបាលជាតិ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជូនលោកវរសេនីយ៍ទោ ស៊ូ បាន អនុប្រធាននាយកដ្ឋានអង្គរក្ស នៃក្រសួងមហាផ្ទៃ

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងលោកវរសេនីយ៍ឯក ស៊ូ បាន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៤២០ អនក្រ.តត
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-យោងតាមការងារចាំបាច់

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងលោក **ឌី សូនីន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក ទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

# ២- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ៦៦ សសរ

### ស្តីពី

### ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់បទល្មើសព្រៃឈើ និងបទល្មើសនៃការបរបាញ់សម្លាប់សត្វព្រៃនៅភូមិភាគខាងលិច នៃខេត្តកោះកុង ខេត្តពោធិសាត់ និងខេត្តបាត់ដំបង

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីប្រកាសលេខ ០១/ប្រក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

-យោងតាមការងារចាំបាច់ របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ជាបន្ទាន់នូវបទល្មើស ព្រៃឈើ និងបទល្មើសនៃការបរបាញ់សម្លាប់សត្វព្រៃនៅភូមិភាគខាងលិចនៃខេត្តកោះកុង ពោធិសាត់ និង បាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម នាយឧត្តមសេនីយ ទៀ បាញ់ | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាប្រធាន |
| ២-ឯកឧត្តម ឃឹុន ហាំង | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | អនុប្រធាន |
| ៣-ឯកឧត្តម នាយឧត្តមសេនីយ កែ គឹមយ៉ាន | អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយឯក ហុក ឡុងឌី | អគ្គនាយកនគរបាលជាតិ | សមាជិក |
| ៥-ឯកឧត្តម ឧត្តមសេនីយឯក ម៉ុល សារឿន | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយឯក មាស សុភា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយឯក សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨-ឯកឧត្តម ច័ន្ទ តុងអ៊ីវ | រដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម ឆាន់ សាផាន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១០-ឯកឧត្តម ខួវ ម៉េងហ៊ាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-ឯកឧត្តម អ៊ុង ចន្ទវឌ្ឍនា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១២-ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

១៣-ឯកឧត្តម ស៊ាន ទិសុទ្ធ សមាជិកអចិន្ត្រៃយ៍អង្គភាពប្រឆាំងរាល់អំពើពុករលួយ សមាជិក

១៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុង សំខាន់ មេបញ្ជាការកងទ័ពជើងទឹក សមាជិក

ប្រការ ២ : គណៈកម្មការចំរុះអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ ៖

-ចុះស្រាវជ្រាវ និងត្រួតពិនិត្យអោយបានច្បាស់លាស់នូវរាល់បទល្មើសព្រៃឈើគ្រប់ប្រភេទ ការធ្វើអាជីវកម្មផល និងអនុផលព្រៃឈើបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ បទល្មើសនៃការជីករ៉ែ ត្បូង និងបទល្មើសនៃការបរបាញ់សម្លាប់សត្វព្រៃ ដែលបង្កឡើងដោយក្រុមជននិយលខូចមួយចំនួន ដើម្បីបំផ្លិចបំផ្លាញនិរន្តរភាពព្រៃឈើ បរិស្ថាន និងសត្វព្រៃនៅក្នុងតំបន់ខាងលើ ។

-លើកវិធានការទប់ស្កាត់ និងបង្ក្រាបជាបន្ទាន់តាមផ្លូវច្បាប់នូវរាល់បទល្មើសខាងលើ អោយមានប្រសិទ្ធភាពនិងស្រាវជ្រាវរកអោយឃើញនូវបុគ្គលដែលបានប្រព្រឹត្តបទល្មើស និងមុខសញ្ញាដែលមានការពាក់ព័ន្ធ ដើម្បីបញ្ជូនខ្លួនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។

-ធ្វើការចរចាជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រថៃ ដើម្បីរកដំណោះស្រាយសមស្របក្នុងកិច្ចសហការទប់ស្កាត់ និង បង្ក្រាបរាល់បទល្មើសខាងលើ ។

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារដែលអនុវត្តបាន និងសុំយោបល់សំរេចពីរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់ ។

ប្រការ ៣ : គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការងារដែលមានសមាសភាព ដូចខាងក្រោម ៖

-ឯកឧត្តម ចន្ទ សារុន អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន

-ឯកឧត្តម ឧត្តមសេនីយឯក មល់ រឿម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និងជានាយរងសេនាធិការចំរុះកងយោធពលខេមរភូមិន្ទ សមាជិក

-ឯកឧត្តម ឧត្តមសេនីយឯក យូ ស៊ុនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

-ឯកឧត្តម ឧត្តមសេនីយឯក ជា តារា នាយកទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

-លោក ប៉ាល់ ច័ន្ទតារា នាយកលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល សមាជិក

-លោក អ៊ឹម អូ ប្រធានការិយាល័យនីតិកម្ម និងវិវាទនៃនាយកដ្ឋានរុក្ខាប្រមាញ់ និងនេសាទ សមាជិក

ទីតាំងនៃលេខាធិការដ្ឋាន គឺអាស្រ័យដោយឯកឧត្តមប្រធានគណៈកម្មការចំរុះអន្តរក្រសួង ធ្វើការកំណត់តាមការជាក់ស្តែង ។

ប្រការ ៤ : គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិប្រើត្រារបស់ក្រសួងការពារជាតិ ដើម្បីសំរួលការងារ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ អភិបាលខេត្តកោះកុង អភិបាលខេត្តពោធិសាត់ អភិបាលខេត្តបាត់ដំបង រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## III- ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០០

**ប្រកាសលេខ ១០៣៧ ឧរថក.ប្រក**

* * *

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២៩៧៥/០០ គ.វ.ក. ចុះថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ។

-បានឃើញលិខិតលេខ ១២៧៩/បស្ថ/សណក ចុះថ្ងៃទី១៦-១១-២០០០ របស់ក្រសួងបរិស្ថាន

-បានឃើញលិខិតលេខ ៤២៩៦/លអ.ស ចុះថ្ងៃទី១៣-១២-១៩៩៦ របស់សាលាក្រុងភ្នំពេញ
-យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊្យូតវ៉េ & ឡារីសាកា ហ្វេសិន ហ្វេកធើរី លីមីធីត ចុះថ្ងៃទី១៦.១០.២០០០

**សំរេច**

ប្រការ ១ : អនុញ្ញាត្តិអោយក្រុមហ៊ុន ស៊្យូតវ៉េ & ឡារីសាកា ហ្វេសិន ហ្វេកធើរី លីមីធីត ( SUIT WAY & LA RISSACA–FASHION FACTORY LIMITED ) តំណាងដោយ លោក CHUEN HAY សញ្ជាតិកាណាដា ភេទប្រុស អាយុ ៥៣ឆ្នាំ កាន់លិខិតឆ្លងដែន លេខ PC 329270 ចុះថ្ងៃទី ០៤-១១-១៩៩៩ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានផ្លាកឈ្មោះថា "រោងចក្រកាត់ដេរ ស៊្យូតវ៉េ និងឡារីសាកា ហ្វេសិន ហ្វេកធើរី លីមីធីត " មានទីតាំងស្ថិតនៅភូមិ ទួលសង្កែ សង្កាត់ទួលសង្កែ ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ប្រការ ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ"កាត់-ដេរសំលៀកបំពាក់"ទៅតាមគំរូដែលតំកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ"ផ្លាកឈ្មោះរោងចក្រ"របស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញ នៅខាងមុខរោងចក្រ ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ើវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រង ធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ ៨ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ស៊្យូតវ៉េ & ឡារីសាកា ហ្វេសិន ហ្វេកធើរី លីមីធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
ហត្ថលេខា និងត្រា
ស៊ុយ សែម